# សភាអឺរ៉ុប ទទូចឱ្យសែប៊ី ពិចារណាឡើងវិញ ពីចំណងទាក់ទង របស់ខ្លួនជាមួយរុស្ស៊ី



គណៈកម្មាធិការគោលនយោបាយការបរទេសនឹងបោះឆ្នោតលើឯកសារព្រាងចាប់ពីថ្ងៃទី១៣-១៤ ខែមិថុនា ឆ្នាំ២០២២ ដែលបន្ទាប់ពីនោះ សមាជិកសភាអឺរ៉ុបនឹងបោះឆ្នោត នៅខែកក្កដា ឆ្នាំ២០២២

EURACTIV ថ្ងៃអង្គារ ១៥កើត ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០២២

សាធារណរដ្ឋសែប៊ី គួរតែបង្ហាញការប្តេជ្ញាចិត្តរបស់ខ្លួន ចំពោះគោលនយោបាយ និងបទដ្ឋានរបស់សហភាពអឺរ៉ុបហើយរំពឹងថា សែប៊ីនឹងពិចារណាឡើងវិញពីចំណងទាក់ទងរបស់ខ្លួនជាមួយសហព័ន្ធរុស្ស៊ី ពាក់ព័ន្ធនឹងវិស័យសេដ្ឋកិច្ច និងការពារជាតិ និងព័ត៌មានក្លែងក្លាយរបស់រដ្ឋាភិបាលវិមានក្រឹមឡាំង។ នេះបើយោងតាមរបាយការណ៍មួយ ដែលនឹងត្រូវបោះឆ្នោតនៅដើមសប្តាហ៍នេះ ដោយគណៈកម្មាធិការគោលនយោបាយការបរទេសនៃសភាអឺរ៉ុប។

គណៈកម្មាធិការខាងលើនឹងបោះឆ្នោតលើឯកសារព្រាងចាប់ពីថ្ងៃទី១៣-១៤ខែមិថុនា ឆ្នាំ២០២២ ហើយបន្ទាប់ពីនោះ សមាជិកសភាអឺរ៉ុបនឹងបោះឆ្នោតសម្រេចនៅក្នុងខែកក្កដា ឆ្នាំ២០២២។ ឯកសារព្រាងនោះ ផ្អែកលើរបាយការណ៍ឆ្នាំ២០២១ របស់គណៈកម្មការអឺរ៉ុប ហើយត្រូវបានបន្ថែមជាមួយនឹងការធ្វើវិសោធនកម្មមួយចំនួន។ ពាក់ព័ន្ធនឹងនីតិវិធីនៃការចូលជាសមាជិកសហភាពអឺរ៉ុបរបស់សែប៊ី គណៈកម្មាធិការបានសរសេរថា វាអាស្រ័យលើថាតើសែប៊ីមានភាពជឿនលឿនប៉ុណ្ណា ក្នុងការអនុម័តជំពូកស្តីពីនីតិរដ្ឋ និងសិទ្ធិជាមូលដ្ឋាន។ សម្រេបតាមគោលនយោបាយការបរទេស សន្តិសុខ និងការពារជាតិរបស់សហភាពអឺរ៉ុប រួមទាំង ការដាក់ទណ្ឌកម្មលើសហព័ន្ធរុស្ស៊ី និងភាពជឿនលឿន ក្នុងការវិលទៅរកប្រក្រតីភាពឡើងវិញនៃចំណងទាក់ទងរវាងសែប៊ី ជាមួយកូសូវ៉ូ ក៏សំខាន់ផងដែរ។

ឯកសារព្រាងដែលផ្អែកលើរបាយការណ៍គណៈកម្មការអឺរ៉ុប បានសំដៅថា សែប៊ីកំពុងតែក្លាយជារដ្ឋមួយ ក្នុងចំណោមរដ្ឋតិចតួចនៅក្នុងទ្វីបអឺរ៉ុប ដែលមិនព្រមចូលរួមក្នុងការដាក់ទណ្ឌកម្មជាអន្តរជាតិលើរុស្ស៊ីឯកសារដដែល ក៏បានទទូចឱ្យអាជ្ញាធររដ្ឋាភិបាលថ្មីរបស់សែប៊ី ត្រូវបង្ហាញនូវ "ការប្តេជ្ញាចិត្តដ៏ពិតប្រាកដ និងប្រកបដោយមហិច្ឆតា ដើម្បីតម្លៃ បទដ្ឋាន និងបទប្បញ្ញត្តិរបស់សហភាពអឺរ៉ុប"។

ឯកសារព្រាងរបស់សភាអឺរ៉ុបក៏បានសរសេរផងដែរថា សែប៊ី គួរតែសម្រេបតាមជាបន្ទាន់ផងដែរ ជាមួយនឹងជំហររបស់សហភាពអឺរ៉ុប និងការសម្រេចចិត្តស្តីពីគោលនយោបាយការបរទេស និងសន្តិសុខ រួមទាំងការដាក់ទណ្ឌកម្មលើបុគ្គលក្រុមនិងអង្គភាពរបស់រុស្ស៊ី និងបេឡារុស ក៏ដូចជា ពិចារណាឡើងវិញលើកិច្ចសហប្រតិបត្តិការរបស់ខ្លួនជាមួយជាមួយរុស្ស៊ី។ សមាជិកសភាអឺរ៉ុបក៏បានបង្ហាញការសោកស្តាយផងដែរ ដែលជើងហោះហើររវាងទីក្រុងបែលហ្គ្រាត-មូស្គូ នៅតែបន្តប្រតិបត្តិការដូចធម្មតា ខណៈដែលសហភាពអឺរ៉ុប បានបិទដែនអាកាសរបស់ខ្លួន ចំពោះយន្តហោះរបស់រុស្ស៊ី៕

*ព័ត៌មានសភាអន្តរជាតិ ១៤-០៦-២២- ឈាវ សុផាត*

ប្រែសម្រួលពី៖ https://www.euractiv.com/section/politics/short_news/eu-parliament-urges-serbia-to-reconsider-relationship-with-russia/

# EU Parliament urges Serbia to reconsider relationship with Russia

Serbia should demonstrate its commitment to the EU's policies and standards and is expected to reconsider its relationship with Russia on the economy, defence and Kremlin disinformation, according to a report to be voted early this week by the European Parliament's foreign policy committee (AFET).

The committee will vote on the draft document from 13-14 June, after which European Parliament lawmakers will vote on it in July. The draft, based on a 2021 report by the European Commission, was supplemented with numerous amendments.

On Serbia's progress toward EU accession, the committee writes that it depends on how Serbia progresses in adopting the chapters on the rule of law and fundamental rights. Complete alignment with the EU's foreign, security and defence policies, including sanctions against Russia, and progress in the normalisation of relations with Kosovo are also crucial.

The Commission's report on which the draft document is based pointed to Serbia being one of the few European states that failed to join international sanctions against Russia. It also urged Serbia's new authorities to demonstrate "a genuine and unambiguous commitment to the values, standards and rules of the EU."

Serbia should also urgently align with the EU's positions and decisions on foreign and security policy, including sanctions against individuals, groups and entities from Russia and Belarus, as well as reconsider its economic cooperation with Russia, the document also writes.

Lawmakers also regretted that the Belgrade-Moscow flights continued to operate normally while the EU had closed its airspace to Russian aircraft.

https://www.euractiv.com/section/politics/short_news/eu-parliament-urges-serbia-to-reconsider-relationship-with-russia/